*ទម្រង់នេះធ្វើឡើងដោយផ្អែកតាមទម្រង់នៅក្នុងតុលាការគ្រួសារប្រទេសជប៉ុន និងសម្របជាមួយបញ្ញត្តិច្បាប់របស់កម្ពុជា សម្រាប់ធ្វើជាឯកសារយោង។ BAKC-JFBA Seminar, March 15, 2018 (Miha Isoi)*

(តម្លៃ ៥០០០រៀល)

# ពាក្យសុំលែងលះតាមការព្រមព្រៀង

## គោរពជូន

ប្រធានសាលាដំបូងរាជធានីភ្នំពេញ

អ្នកដាក់ពាក្យសុំ B ៖ ផ្ទះលេខ ១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ភាគីម្ខាងទៀត A ៖ ផ្ទះលេខ 34 សង្កាត់ផ្សារកណ្ដាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ផ្នែកទី១ ដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ
១. ការលែងលះរវាងអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត

ផ្នែកទី២ មូលហេតុនៃការដាក់ពាក្យសុំ
១. អ្នកដាក់ពាក្យសុំបានរៀបការជាមួយភាគីម្ខាងទៀតនៅថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០០៥ ហើយកូនស្រី C បានកើតនៅថ្ងៃទី ២ ខែមេសាឆ្នាំ ២០០៧ ដែលមានអាយុ ១០ ឆ្នាំ។

២. អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរស់នៅជាមួយគ្នាអស់រយៈពេល ១២ ឆ្នាំបន្ទាប់ពីរៀបការ។ ក្រោយមក ក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះភាគីម្ខាងទៀតជារឿយៗផឹកស្រា យកលុយទៅផឹកហើយជួនកាលថែមទាំងប្រើអំពើហិង្សាផង។ ដូច្នេះហើយ អ្នកដាក់ពាក្យសុំបានចាកចេញពីផ្ទះរបស់ខ្លួននៅដើមខែធ្នូ ឆ្នាំ 2017 ជាមួយកូនស្រី C ទៅរស់នៅជាមួយឪពុកម្ដាយវិញ។ អ្នកដាក់ពាក្យសុំ ចង់លែងលះគ្នាជាមួយភាគីម្ខាងទៀត ។

៣. ភាគីម្ខាងទៀតក៏យល់ព្រមជាមួយអ្នកដាក់ពាក្យសុំដែរ។

៤. កូនស្រី C ចង់រស់នៅជាមួយអ្នកដាក់ពាក្យសុំ ហើយភាគីម្ខាងទៀតក៏យល់ព្រមដែរ។

៥. ភាគីម្ខាងទៀត បានព្រមព្រៀងបង់ប្រាក់ ៦០០.០០០ រៀលនៅរៀងរាល់ចុងខែ ចាប់ពីខែមេសាឆ្នាំ ២០១៨ ដល់ខែមេសា ឆ្នាំ ២០២២ និង ៩០០.០០០ រៀលពីខែឧសភា ឆ្នាំ ២០២២ ដល់ខែមេសា ឆ្នាំ ២០២៥ ទៅឲ្យអ្នកដាក់ពាក្យសុំសម្រាប់ការចំណាយសម្រាប់ការចិញ្ចឹមកូនស្រី C។

៦. ភាគីម្ខាងទៀតបានយល់ព្រមបង់ប្រាក់ចំនួន ៤0 លានរៀលដល់អ្នកដាក់ពាក្យសុំ សម្រាប់ការបែងចែកទ្រព្យសម្បត្តិរួម។

ភ្នំពេញថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០១៨

(ស្នាមមេដៃ)

អ្នកដាក់ពាក្យសុំ B

(ហត្ថលេខា និង ត្រា)

អ្នកតំណាងនៃអ្នកដាក់ពាក្យសុំ B, មេធាវី D

ការិយាល័យច្បាប់ Orange

ជាន់ទី ២៤, អគារភ្នំពេញ, លេខ ៤៤៥, មហាវិថីព្រះមនីវង្ស, ខណ្ឌ ៧ មករា, រាជធានីភ្នំពេញ,

**ឯកសារភ្ជាប់**

១. សំបុត្រអាពាហ៍ពិពាហ៍

២. សំបុត្រកំណើត C